**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៤១ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩៩៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋឆ្លងដែនដែលមានអង្គការចាត់តាំង
- យោងសេចក្តីសម្រេចលេខ ៣៥សសរ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងសមាសភាពក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀងអនុស្សារណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ស ម្រេ ច**

ប្រការ១ : ត្រូវបានតែងតាំងក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដូចតទៅ :

១-ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម **អង្គវង្ស វឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សមាជិក

៣-ឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការនគរបាលជាតិ សមាជិក

៤-លោកជំទាវ **យូ អយ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក

៥-ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋលេខាធិការ ក្រសួងអប់រំយុវជន និងកីឡា សមាជិក

៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក **នេត សាវឿន** អគ្គស្នងការរងនគរបាលជាតិ សមាជិក

៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក **វង្ស ពិសេន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

ប្រការ២ : ក្រុមការងារជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដែលមានភារកិច្ចដូចខាងក្រោម :

- ដឹកនាំសំរបសំរួលជាមួយសមាជិក សមាជិកានៃ គ.អ.ល.ជ ដើម្បីអនុវត្តអោយបានសំរេចសេចក្ដីសម្រេចលេខ ១៣សសរ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្ដាប្រទេសពាក់ព័ន្ធ ស្ដីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ ។
- ជំរុញ តាមដាន ត្រួតពិនិត្យ រំលឹកដាស់តឿន អាជ្ញាធរខេត្ត-ក្រុង កងកម្លាំងនគរបាលជាតិ កងរាជ-អាវុធហត្ថ និងក្រសួងស្ថាប័នពាក់ព័ន្ធ បើកយុទ្ធនាការក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។
- លុបបំបាត់និទណ្ឌភាព ដោយជំរុញអោយមានការកាត់ទោស មេក្លោង ជនល្មើសពាក់ព័ន្ធដល់អំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារអោយបានជាអតិបរមា ។
- លើកផែនការអោយអាជ្ញាធរមូលដ្ឋាន និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការផ្សព្វផ្សាយ ឃោសនាអប់រំអំពីច្បាប់ លិខិតុបករណ៍ជាតិ អន្តរជាតិ ពាក់ព័ន្ធនានា ក៏ដូចជាគ្រោះមហន្តរាយដែលបណ្ដាលមកពីអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើពលកម្មមនុស្ស និងការធ្វើអាជីវកម្មលើស្ត្រី និងកុមារ ដល់សាធារណៈជន ជាពិសេសជនងាយរងគ្រោះអោយបានយល់ជ្រួតជ្រាប ។

ប្រការ៣ : - ក្រុមការងារអាចបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ដែលមានទីតាំងស្ថិតនៅទីស្ដីការក្រសួងមហាផ្ទៃ ដោយប្រើប្រាស់មន្ត្រីរបស់សាមីស្ថាប័ននិមួយៗ ដើម្បីជាជំនួយក្នុងការតាមដាន ត្រួតពិនិត្យ ការចាត់

តាំងអនុវត្ត ការផ្តើមស្នើគោលការណ៍ វិធានការក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើពលកម្មមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ព្រមទាំងបូកសរុបរបាយការណ៍សកម្មភាពនៃយុទ្ធនាការ ។

- សមាសភាពនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានក្រុមការងារ ។
- ក្រុមការងារមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

ប្រការ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង និងសមាសភាពដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៧

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និងប្រការ៤
- ប្រធានក្រុមការងារ ក.អ.ល.ជ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ